# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

## ឧបនាយករដ្ឋមន្ត្រីអូស្ត្រាលី នឹងបំពេញទស្សនកិច្ចនៅកម្ពុជា និងវៀតណាម

ឯកឧត្តម រីឆេដ ម៉ាល ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិអូស្ត្រាលី នឹងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា និងវៀតណាម ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២២។

ផ្អែកលើកិច្ចប្រជុំកំពូលអាស៊ានប្រកបដោយភាពជោគជ័យ ដែលចូលរួមដោយឯកឧត្តម អេនសូនី អាល់បូនីស៊ី នាយករដ្ឋមន្ត្រីអូស្ត្រាលី កាលពីពីរសប្តាហ៍មុន ឯកឧត្តមរីឆេដ ម៉ាល ឧបនាយករដ្ឋមន្ត្រីអូស្ត្រាលី នឹងចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក លើកទី៩ (ADMM-Plus) នៅថ្ងៃទី២៣ ខែវិច្ឆិកា។

កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក ADMM-Plus ជាកិច្ចសន្ទនាការពារជាតិជាន់ខ្ពស់ របស់តំបន់ ដែលផ្តល់វេទិកាមួយដើម្បីពិភាក្សាអំពីបញ្ហាប្រឈមសំខាន់ៗ ដែលឥណ្ឌូប៉ាស៊ីហ្វិកកំពុងប្រឈមមុខ។

ក្នុងពេលនៅកម្ពុជាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី នឹងជួបជាមួយសមភាគីមួយចំនួនរួមមានទាំងជំនួបជាមួយ សម្តេចសេនាពិជ័យ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិរបស់កម្ពុជា ផងដែរ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏នឹងបំពេញទស្សនកិច្ចនៅប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ផងដែរ ដើម្បីចូលរួមបើកកិច្ចប្រជុំជាន់ខ្ពស់រដ្ឋមន្ត្រីការពារជាតិ ជាមួយនាយឧត្តមសេនីយ៍ Phan Van Giang រដ្ឋមន្ត្រីក្រសួងការពារជាតិវៀតណាម។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏នឹងជួបជាមួយ ថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួន របស់រដ្ឋាភិបាលវៀតណាម ផងដែរ។

ដំណើរទស្សនកិច្ចនេះ ពង្រឹងសារៈសំខាន់របស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការលើកកំពស់ទំនាក់ទំនងដ៏រឹងមាំជាប្រវត្តិសាស្ត្ររបស់អូស្ត្រាលី ជាមួយអាស៊ីអាគ្នេយ៍។

ខាងក្រោមនេះ ជាប្រសាសន៍របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រីឆេដ ម៉ាល

*ទាក់ទងនឹង កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក ADMM-Plus៖*

"វាជាកិត្តិយសណាស់ ក្នុងការចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក លើកទី៩ ADMM-Plus នៅខេត្តសៀមរាប។"

"អាស៊ានជាស្នូលនៃចក្ខុវិស័យរបស់ប្រទេសអូស្ត្រាលី សម្រាប់តំបន់ដែលបើកចំហ ប្រកប ដោយបរិយាបន្ន និងមានភាពធន់ ដែលបង្កើតឡើងផ្អែកច្បាប់អន្តរជាតិ។"

"វាពង្រឹងការប្តេជ្ញាចិត្តរបស់យើង ចំពោះតំបន់ដែលប្រទេសទាំងអស់ ទាំងតូច ទាំងធំ មានសេរីភាព ក្នុងការអនុវត្តអធិបតេយ្យភាពរបស់ពួកគេ។"

"អូស្ត្រាលីគាំទ្រយ៉ាងមុតមាំ នូវគោលការណ៍នានា ដែលមានចែងក្នុងទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ដែលគាំទ្រចក្ខុវិស័យនេះ។"

*ទាក់ទងនឹងការបើកកិច្ចប្រជុំជាន់ខ្ពស់រដ្ឋមន្ត្រីការពារជាតិអូស្ត្រាលី និងវៀតណាម៖*

"អូស្ត្រាលី និងវៀតណាមមានទំនាក់ទំនងរឹងមាំ និងរីកចម្រើន ហើយខ្ញុំទន្ទឹងរង់ចាំបើកកិច្ចប្រជុំជាន់ខ្ពស់នេះ ជាមួយឧត្តមសេនីយ៍ Giang ។"

"វិស័យការពារជាតិបានរួមចំណែកយ៉ាងសំខាន់ ដល់ភាពជាដៃគូយុទ្ធសាស្ត្ររបស់យើងរួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការយូរអង្វែងរបស់យើង លើការអប់រំ និងការបណ្តុះបណ្តាល និងការរក្សាសន្តិភាព"។

**កំណត់សម្គាល់សម្រាប់អ្នកសារព័ត៌មាន៖**

អ្នកសារព័ត៌មានអាចយករូបថតអំពីទស្សនកិច្ចនេះ ពី http://images.defence.gov.au/S20223767

**ទំនាក់ទំនងព័ត៌មាន៖**

ការិយាល័យរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រីឆេដ ម៉ាល

dpm.media@defence.gov.au

02 6277 7800

ក្រសួងការពារជាតិអូស្ត្រាលី media@defence.gov.au